ក

## មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៩-៨-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២១៩ ស្តីពីការតែងតាំងមុខងារជូន ឯកឧត្តម ឧត្តមសេនីយ៍ទោ **សំ ចន្ទ្ធរ៉ុន** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ជាអគ្គលេខាធិការ ក្រសួងការពារជាតិ ១៩២៣

២៩-៨-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២២០ ស្តីពីការផ្តល់សញ្ជាតិខ្មែរ:

១- ដោយអាពាហ៍ពិពាហ៍ ជូន លោកស្រី **ហូ លីស៊ីវស៊ា** ( HOU LU HSIU-SHIA ) ឈ្មោះហៅក្រៅ **លី ស៊ីវស៊ា** (LU HSIU-SHIA) សញ្ជាតិដើមចិន កើតនៅ កោះតៃវ៉ាន់ ប្រទេសចិន

២- ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនកញ្ញា **ហូ យ៉ាឃី** (HOU YA CHI) សញ្ជាតិដើមចិន កើតនៅ កោះតៃវ៉ាន់ ប្រទេសចិន ១៩២៤

៣០-៨-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២២១ ស្តីពីការតែងតាំងឯកឧត្តម **ចិន ឈិន** ជាប្រធាន ក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ ឆ្នាំ លើកទី ៣ ១៩២៥

៣០-៨-២០០៤ -ព្រះរាជក្រឹត្យនស/រកត/០៨០៤/២២២ ស្តីពីការតែងតាំងឯកឧត្តម **យោង យុន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារឧស្សាហកម្មរ៉ែ និងថាមពល មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ១៩២៦

៣០-៨-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២២៣ ស្តីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ **យិន សារ៉ាន់** ជាជំនួយការផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ១៩២៧

៣០-៨-២០០៤ -ព្រះរាជក្រឹត្យនស/រកត/០៨០៤/២២៤ ស្តីពីការតម្លើងឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ជូនឯកឧត្តម **ឌីថ សុខហាក់** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារច្បាប់ ១៩២៨

៣០-៨-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២២៥ ស្តីពីការតែងតាំងឯកឧត្តម **កៅ ខុនជារ៉េត** ជាទីប្រឹក្សាសម្តេច **ក្រុមព្រះ នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទទួលការងារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ១៩២៩

៣១-៨-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២២៦ ស្តីពីការប្រទានគោរមងារ **សម្តេច នរោត្តម យុវនាថ** ជា **សម្តេច ព្រះបរមរាមា នរោត្តម យុវនាថ** ១៩៣០

| | | |
|---|---|---|
| ៣១-៨-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២២៧ ស្តីពីការប្រទានគោរម្យងារ **សម្តេច នរោត្តម ចក្រពង្ស** ជា **សម្តេច ព្រះមហិស្សរា នរោត្តម ចក្រពង្ស** | ១៩៣១ |
| ៣១-៨-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២២៨ ស្តីពីការប្រទានគោរម្យងារ **សម្តេច នរោត្តម សីហមុនី** ជា **សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** | ១៩៣២ |
| ៣១-៨-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២២៩ ស្តីពីការប្រទានគោរម្យងារ **សម្តេច នរោត្តម អរុណរស្មី** ជា **សម្តេច រាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** | ១៩៣៣ |
| ៣១-៨-២០០៤ | - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២៣០ ស្តីពីការបញ្ចប់តំណែងទីប្រឹក្សា និង ឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំង មុនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ និងត្រូវបានតែងតាំងឯកឧត្តម លោកជំទាវ ចំនួន ១៤ រូប ជាទីប្រឹក្សា និង ឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា | ១៩៣៤ |
| ៣១-៨-២០០៤ | - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២៣១ ស្តីពីការបញ្ចប់តំណែងទីប្រឹក្សា និង ឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំង មុនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ និងត្រូវបានតែងតាំងឯកឧត្តម លោកជំទាវ ចំនួន ២១ រូប ជាទីប្រឹក្សា និង ឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា | ១៩៣៦ |
| ៣១-៨-២០០៤ | - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២៣២ ស្តីពីការបញ្ចប់តំណែងនាយក និង នាយករង ខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាដែលបានតែងតាំង មុន ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ និងត្រូវបានតែងតាំងឯកឧត្តម លោកជំទាវចំនួន ០៧ រូប ជា នាយកនិងនាយករងខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា | ១៩៣៨ |
| ៣១-៨-២០០៤ | - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២៣៣ ស្តីពីការតែងតាំងឯកឧត្តម **ម៉ុន ថាវ** ជាឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | ១៩៤០ |
| ៣១-៨-២០០៤ | - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២៣៤ ស្តីពីការតែងតាំងសមាសភាពដឹកនាំ និងទីប្រឹក្សា អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ | ១៩៤១ |
| ៣១-៨-២០០៤ | - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២៣៥ ស្តីពីការតម្លើងឋានៈជូនមន្ត្រីចំនួន ០៣ រូប នៃ អជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | ១៩៤២ |
| ៣១-៨-២០០៤ | - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២៣៦ ស្តីពីការកែតម្រូវ មាត្រា ១ និងមាត្រា ២ នៃព្រះ រាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការ បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ១៩៤៣ |
| ៣១-៨-២០០៤ | - ព្រះរាជក្រឹត្យ នស/រកត/០៨០៤/២៣៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍន៍ ហៅកាត់ថា "**គ.ជ.ប.អ**" | ១៩៤៦ |

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


២៤-៨-២០០៤ -អនុក្រឹត្យលេខ ៣៩ អនក្រ.បក ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ១៥៥១

២៦-៨-២០០៤ -អនុក្រឹត្យលេខ ៤០ អនក្រ.បក ស្តីពីការប្រគល់សិទ្ធិកាន់កាប់ទីតាំងដីដែលមានប័ណ្ណសំគាល់សិទ្ធកាន់កាប់អចលនវត្ថុលេខ សរ. ០០០៦៦៨ ចុះថ្ងៃទី ២៥-១-៩៦ ១៥៥៥

២៦-៨-២០០៤ -អនុក្រឹត្យលេខ ៤១ អនក្រ.បក ស្តីពីការបង្កើតរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ ១៥៥៧

២៧-៨-២០០៤ -អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការបែងចែកឥណទានចំណាយថវិការបស់ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុវនីតិសម្បទា ក្រសួងអប់រំយុវជន និង កីឡា និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៤ ១៥៦១

២៤-៨-២០០៤ -អនុក្រឹត្យលេខ ៤៧៧ អនក្រ.តត ស្តីពីការតែងតាំងមុខងារនាយទាហាន ១៥៦៣

២៤-៨-២០០៤ -អនុក្រឹត្យលេខ ៤៧៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៦៥

២៥-៨-២០០៤ -អនុក្រឹត្យលេខ ៤៧៩ អនក្រ.តត ស្តីពីការតែងតាំងប្រធាន និង សមាជិកក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១៥៦៦

២៥-៨-២០០៤ -អនុក្រឹត្យលេខ ៤៨០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៦៨

២៥-៨-២០០៤ -អនុក្រឹត្យលេខ ៤៨១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៦៩

២៥-៨-២០០៤ -អនុក្រឹត្យលេខ ៤៨២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៧០

២៦-៨-២០០៤ -អនុក្រឹត្យលេខ ៤៨៣ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១៥៧១

២៦-៨-២០០៤ -អនុក្រឹត្យលេខ ៤៨៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៥៧២

២៦-៨-២០០៤ -អនុក្រឹត្យលេខ ៤៨៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៥៨៤

២៦-៨-២០០៤ -អនុក្រឹត្យលេខ ៤៨៦ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១៥៨៥

២៧-៨-២០០៤ -អនុក្រឹត្យលេខ ៤៨៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៥៨៦

២៧-៨-២០០៤ -អនុក្រឹត្យលេខ ៤៨៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៥៨៧

២៧-៨-២០០៤ -អនុក្រឹត្យលេខ ៤៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៥៨៨


### ២.សេចក្តីសំរេច


២៤-៨-២០០៤ -សេចក្តីសំរេចលេខ ៤៩ សសរ ស្តីពីការបន្តការងាររបស់គណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវយកទៅតាំងពិពណ៌នៅសាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ដី និងប្រទេសអេស្ប៉ាញ ១៥៨៩

២៤-៨-២០០៤ -សេចក្តីសំរេចលេខ ៥០ សសរ ស្តីពីការផ្លាស់ប្តូរប្រធានគណៈកម្មការចំរុះ ចុះបង្ក្រាបបទល្មើស ព្រៃឈើ នៅតំបន់កន្ទុយនាគ ក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគីរី ១៩៩២

២៦-៨-២០០៤ -សេចក្តីសំរេចលេខ ៥១ សសរ ស្តីពីការកែតម្រូវសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ១៩៩៤

២៧-៨-២០០៤ -សេចក្តីសំរេចលេខ ៥២ សសរ ស្តីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ១៩៩៧

២៩-៨-២០០៤ -សេចក្តីសំរេចលេខ ៥៣ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ២០០០


## ៣_សារាចរណែនាំ


២៤-៨-២០០៤ -សារាចរណែនាំលេខ ០៨ សរណន ស្តីពីការប្រារព្ធទិវាអក្សរកម្មជាតិ ៨ កញ្ញា ២០០១

២៧-៨-២០០៤ -សារាចរណែនាំលេខ ០៩ សរណន ស្តីពីការពង្រឹងវិធានការការពារសន្តិសុខ និងសុវត្ថិភាព ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ២០០៤


## III_ការខារបណ្ណាក្រសួខ

### ១_ឌីស្តីការរដ្ឋមន្ត្រីក្រសួខពាណិជ្ជកម្ម


៣១-៨-២០០៤ -ប្រកាសលេខ ១៦៨ MOC/M2004 ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំការបោះឆ្នោត ជ្រើសរើសសមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្ត-ក្រុង ២០០៧


### ២_ឌីស្តីការរដ្ឋមន្ត្រីក្រសួខកសិកម្ម រុក្ខាប្រមាញ់ និខ នេសាន


២៥-៨-២០០៤ -ប្រកាសលេខ ២៧១ ប្រក.កសក ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសម្គាល់របស់សមត្ថកិច្ច ភូតគាមអនាម័យ ២០០៩


### ៣_ឌីស្តីការរដ្ឋមន្ត្រីក្រសួខរៀបចំដែនដី នគរូបនីយកម្ម និខ សំណខ់


៣១-៨-២០០៤ -ប្រកាសលេខ ១៤៧ ប្រក.ដនស/ផសហ ស្តីពីការបង្កើត គណៈកម្មាធិការកំណត់បុរេលក្ខណៈ សម្បត្តិ វាយតម្លៃ ប្រគល់កិច្ចសន្យា ( PEAC) និង បង្កើតអង្គភាពលទ្ធកម្ម (PU) របស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ២០១៥

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/២១៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១: តែងតាំងមុខងារ ជូន ឯកឧត្តម ឧត្តមសេនីយ៍ទោ **សំ វណ្ណថន** អត្តលេខ ០០០២០៥ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ជា អគ្គលេខាធិការ ក្រសួងការពារជាតិ ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រល.០៤.០៨.២២០

លេខ: ១៧៨៩.ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឺ តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/៧២០

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ .-**

- ផ្តល់សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ជូនអ្នកស្រី ហូ លីស៊ីវស៊ា ( HOU LU HSIU-SHIA ) ឈ្មោះហៅក្រៅ លី ស៊ីវស៊ា (LU HSIU-SHIA) សញ្ជាតិដើមចិន កើតថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៤៩ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

- ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបន័យកម្ម ជូនកញ្ញា ហូ យ៉ាឃី ( HOU YA CHI ) សញ្ជាតិដើមចិន កើតថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៥ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា២ .-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៣ស.០៤-០៨.៧២១

លេខៈ ១៧៧៨-ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ សីហា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឈាង៉ី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/៧៧១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេច ខៅ សែនកុសល ឈុំ អធិបតីនៃសម័យប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៤ ដើម្បីជ្រើសតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៣ ឆ្នាំ ២០០៤ - ២០០៧ ។

## ត្រាស់បង្គាប់

**មាត្រា ១.-** តែងតាំងឯកឧត្តម **ចិន ឈិន** ជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៣ ។

**មាត្រា ២.-** ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

៣៧ល.០៤០៨.៧៧៧

**ជា ស៊ីម**

**ប្រមុខរដ្ឋស្តីទី**

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤ / ៧២២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

មាត្រា ១: តែងតាំង ឯកឧត្តម **យាង ឃុន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារឧស្សាហកម្ម រ៉ែ និងថាមពល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រស.០៤០៨.៧២៣

លេខ: ១៨០ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/៧២៣

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលព្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលព្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងឯកឧត្តមឧត្តមសេនីយ៍ទោ **យិន សារ៉ាន់** ជាជំនួយការផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤
គ្រួងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

៣រល.០៤០៥.៧២៤

លេខៈ ១៨១ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០៤/៧៦៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

មាត្រា១: តម្លើងឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ជូនឯកឧត្តម ជីង សុងហាត់ ទីប្រឹក្សាសម្តេច ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារច្បាប់ ។

មាត្រា២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣កស.០៤០៥.៧៦៥
លេខ: ១៨៧ ចបល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណារី គាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/៧២៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-**

តែងតាំង ឯកឧត្តម គៅ ខុនដារ៉ែត ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទទួលការងារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា ២ .-**

ប្រធានរដ្ឋសភា និងសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ខែ សីហាឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣ល.០៨០៤.៧២៦

លេខ: ៦៧៩ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុណាឌី. តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២២៦

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រទានគោរម្យងារ**

**សម្ដេច នរោត្តម យុវនាថ**

**ជា**

**សម្ដេច ព្រះបរមរាមា នរោត្តម យុវនាថ**

ព្រះហស្ថលេខា
នរោត្តម សីហនុ

ការ.០៤០៩.៧៧៧
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**
ធ្វើនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ: រ.ចក
រាជធានីភ្នំពេញ ,ថ្ងៃទី ខែ ឆ្នាំ២០០៤
សម្ដេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្ការ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ: ៧៧០ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ[illegible] ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
សៅ ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២២៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានគោរម្យងារ

សម្តេច នរោត្តម ចក្រពង្ស

ជា

សម្តេច ព្រះមហិស្សរា នរោត្តម ចក្រពង្ស

ព្រះហស្តលេខា
នរោត្តម សីហនុ

៣រល.០៤០៨.២២៨
បានប្រថាប់ព្រះរាជលញ្ឆករហើយ
ធ្វើនៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខៈ រ.ចច
រាជធានីភ្នំពេញ ,ថ្ងៃទី ខែ ឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខៈ [illegible] ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២២៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានគោរមងារ

សម្តេច នរោត្តម សីហមុនី

ជា

សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

ព្រះហស្តលេខា
នរោត្តម សីហនុ

៣.ល.០៨០៨.៧២៩
បានប្រថាប់ព្រះរាជលញ្ចករហើយ
ធ្វើនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ: រ.ចច
រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វររាជជ័យ អធិបតីស្រីវរ៉ា
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ: ៧០៣ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
 សុខ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២២៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានគោរម្យងារ

សម្តេច នរោត្តម អរុណរស្មី

ជា

សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី

ព្រះហស្តលេខា

នរោត្តម សីហនុ

ចារ.០៤០៩.២៣០

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ: រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៤
សម្តេចចៅហ្វាវាំង វររាជជ័យ អធិបតីស្រីវង្ករ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា និងត្រា
គង់ សំអុល

លេខ: ៧១០ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកញ្ញា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង ធាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/៧៣០

យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/ ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-យោងតាមសំណើរបស់ **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១៩៦ រស ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៤

-យោងតាមការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា១ .-** ត្រូវបានបញ្ចប់តំណែងទីប្រឹក្សានិងឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំង មុនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ។

**មាត្រា២ .-** ត្រូវបានតែងតាំងឯកឧត្តម លោកជំទាវ ចំនួន ១៤ រូប ជាទីប្រឹក្សា និងឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **សាវ៉ិយ៉េ ដាប់ហ្វ្រាន់** | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២-ឯកឧត្តម **ឡៅម សារិន** | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៣-លោកជំទាវ **ម៉ែន គ្រីស្ទីន** | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៤- ឯកឧត្តម **នរោត្តមរណឫទ្ធិ អាណានជាឃាទ** | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋមន្ត្រី |

៥-ឯកឧត្តម សុត ចមរ៉ានឫទ្ធិ ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ
៦-ឯកឧត្តម សុះ អឿ ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៧-ឯកឧត្តម សំ សេរី ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៨-ឯកឧត្តម ពេជ គឹមអេង ជាឧបការីប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៩-ឯកឧត្តម ចាន់ ណារ៉ា ជាឧបការីប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១០-ឯកឧត្តម យ៉ឹម យន់ ជាឧបការីប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១១-ឯកឧត្តម ឆុច ចណ្ណា ជាឧបការីប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១២-ឯកឧត្តម ពេជ្រ សុខុម ជាឧបការីប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៣-ឯកឧត្តម យត់ ឈុនឡេង ជាឧបការីប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ
១៤-លោកជំទាវ ទឹម រ៉េនី ជាឧបការីប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

**មាត្រា៣ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវមទូលបន្ទុកអនុវត្តឱ្យបានសម្រេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤
ក្នុងព្រះបរមនាមនិងតាមព្រះរាជបន្ទូលបង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

៣រស.០៤០៨.៧៣១

លេខ: ៧៣១ ចល
**ចម្លងចេញពីច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សារ៉ាន់ ឈួន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/៧៣១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
-យោងតាមសំណើរបស់ **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ១៥២ រស ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០៤
-យោងតាមការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា១** .- ត្រូវបានបញ្ចប់តំណែងទីប្រឹក្សានិងឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំងមុនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ។

**មាត្រា២** .- ត្រូវបានតែងតាំងឯកឧត្តម លោកជំទាវ ចំនួន ២១ រូប ជាទីប្រឹក្សា និងឧបការី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១-ឯកឧត្តម **ឃុន ភ័ណ្ឌប** | ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២-ឯកឧត្តម **ឃឹន យាន** | ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៣-ឯកឧត្តម **ម៉ីន សារឿន** | ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៤-ឯកឧត្តម **ជៀម អ៊ុន** | ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៥-ឯកឧត្តម **សូ ជី** | ជាទីប្រឹក្សាប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋមន្ត្រី |

| | | |
|---|---|---|
| ៦-ឯកឧត្តម ឡេង ដែល | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៧-ឯកឧត្តម ជា ចំនួសារិន | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៨-ឯកឧត្តម ផន ចន្ថា | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៩-ឯកឧត្តម ម៉េង លី | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ១០-ឯកឧត្តម មាឌ្យ យុទ្ធ | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ១១-ឯកឧត្តម ឡឹក ជូឈាល់ | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ១២-ឯកឧត្តម ឡោ សារី | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ១៣-ឯកឧត្តម សាយ មង្គល | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៤-ឯកឧត្តម ឈឹម សោភ័ណ្ឌ | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៥-ឯកឧត្តម ឌាន់ សិទ្ធី | ជាទីប្រឹក្សាប្រធានរដ្ឋសភា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៦-ឯកឧត្តម ទាន់ សុវណ្ណមុនី | ជាឧបការីប្រធានរដ្ឋសភា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៧-ឯកឧត្តម អ៊ីត សាខន | ជាឧបការីប្រធានរដ្ឋសភា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៨-ឯកឧត្តម ហេង ហាស៊ីម | ជាឧបការីប្រធានរដ្ឋសភា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៩-លោកជំទាវ នូ ដារី | ជាឧបការីប្រធានរដ្ឋសភា | បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ២០-ឯកឧត្តម កាន់ សុធា | ជាឧបការីប្រធានរដ្ឋសភា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ២១-ឯកឧត្តម ខាត់ ណារិទ្ធ | ជាឧបការីប្រធានរដ្ឋសភា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

**មាត្រា៣ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ៣១ខែ សីហា ឆ្នាំ ២០០៤*

*ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់*

**ប្រមុខរដ្ឋស្តីទី**

នស.០៤០៨.២៣៤

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ ៤៧០៤ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០០៤

**រដ្ឋលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២៣២

យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត ជីសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- យោងតាមសំណើរបស់ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១៥១ រស ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៤
- យោងតាមការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានបញ្ចប់តំណែងនាយក និងនាយករងខុទ្ទកាល័យសម្តេចក្រុមព្រះ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំង មុនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ។

**មាត្រា២** : ត្រូវបានតែងតាំងឯកឧត្តម លោកជំទាវ ចំនួន ០៧ រូប ជានាយក និងនាយករងខុទ្ទកាល័យ សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១- អ្នកអង្គម្ចាស់ក្សត្រីយ៍ | **ស៊ីសុវត្ថិ អែរ៉ាទ៉ាឌី** | ជានាយិកាខុទ្ទកាល័យសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២- ឯកឧត្តម | **ម៉ា ជន** | ជានាយករងខុទ្ទកាល័យសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣- ឯកឧត្តម | **អ៊ី ពិសិដ្ឋ** | ជានាយករងខុទ្ទកាល័យសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

៤- ឯកឧត្តម **ខៀវ ស៊ិណាត** ជានាយករងខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម **សោម ប៊ុនធឿន** ជានាយករងខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម **ទ្រាំ សាយហេង** ជានាយករងខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៧- ឯកឧត្តម **នៅ យ៉ាណារិទ្ធ** ជានាយករងខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

**មាត្រា៣ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

*៣រល.០៨០៤.២៣៣*

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ: ៧០៥ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវ៉ី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/៧៣៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-**

តែងតាំង ឯកឧត្តម ម៉ឹន ថៅ ជាឧបការីប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ .-**

ប្រធានរដ្ឋសភា និងសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ខែ សីហាឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣រល.០៤០៨.៧៣៤ លេខ ១៩៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០... ខែ ... ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាឌី តាន់

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

# ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨០៤/២៣៤

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០១០០/០០៧ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០០/១២៦ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការតែងតាំង និងតម្កល់ទុកអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

តែងតាំងសមាសភាពដឹកនាំ និងទីប្រឹក្សា អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម ម៉ៅ សំអឿន | ជាអនុប្រធានទី ១ | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២- ឯកឧត្តម ម៉ិន លាងហេង | ជាទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៣- ឯកឧត្តម គិន លីហេង | ជាទីប្រឹក្សា | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣៧៤-០៨០៤/២៣៤
លេខៈ ៩៨៦ ចល
ដើម្បីចម្លងចែកផ្សាយ
រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/៧៣៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានតម្លើងឋានៈជូនមន្ត្រីចំនួន ០៣ រូប នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ញឹក ឆេង ជាអគ្គលេខាធិការរង មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២- ឯកឧត្តម ខៀវ សុជា ជាអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តមឧត្តមសេនីយទោ សែម សុវណ្ណនី ជាអគ្គលេខាធិការរង មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

ពរណ.០៨០៨.៧៣៦ លេខ: ១៨៣៥ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារិទ្ធ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២៣៦

យើង
ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

មាត្រា ១ និងមាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានកែតម្រូវដូចខាងក្រោម :

**មាត្រា ១ថ្មី.-**

បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយហៅកាត់ថាគ.ជ.គ.ម និងជាអក្សរឡាតាំង ហៅកាត់ថា NCDM មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី១ |
| ៣- ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី២ |
| ៤- រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ | អនុប្រធាន |

| | |
|---|---|
| ៥- រដ្ឋមន្ត្រី ក្រសួងការពារជាតិ | អនុប្រធាន |
| ៦- រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩- រដ្ឋមន្ត្រី ក្រសួងបរិស្ថាន | សមាជិក |
| ១០- រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១១- រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣- រដ្ឋមន្ត្រី ក្រសួងសុខាភិបាល | សមាជិក |
| ១៤- រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥- រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៦- រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៧- រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៨- រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៩- រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី | សមាជិក |
| ២០- តំណាង អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២១- តំណាងប្រធានសមាគមជាតិកាកបាទក្រហមកម្ពុជា | សមាជិក |
| ២២- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |

**មាត្រា ២ថ្មី.-**

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានភារកិច្ចដូចតទៅ :

ក- អង្កេត តាមដាន វាយតម្លៃ ប្រមូល វិភាគ គ្រប់គ្រងទិន្នន័យគ្រោះភ័យនៃគ្រោះមហន្តរាយ និងរៀបចំចងក្រងរបាយការណ៍ស្តីពីស្ថានភាពគ្រោះមហន្តរាយ ដើម្បីផ្តល់យោបល់ជូនរាជរដ្ឋាភិបាលដាក់ចេញនូវគោលការណ៍ គោលនយោបាយ សារាចរ សេចក្តីប្រកាស និងវិធានការសំរាប់ការគ្រប់គ្រងគ្រោះមហន្តរាយ

ខ- លើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការ និងការប្រើប្រាស់ប្រភពធនធាន ដូចជាមូលនិធិ សម្ភារៈ ប្រេងឥន្ធនៈ មធ្យោបាយប្រើប្រាស់ និងធនធានមនុស្សដើម្បីដំណើរការកិច្ចប្រតិបត្តិការការងារគ្រប់គ្រងគ្រោះមហន្តរាយ និងសំរាប់ជួយដល់ជនរងគ្រោះដែលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស

គ- អភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រីទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ ក្រសួងពាក់ព័ន្ធ ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ និងអប់រំផ្សព្វផ្សាយការយល់ដឹងសាធារណៈដល់ប្រជាពលរដ្ឋ នៅសហគមន៍អំពីគ្រោះភ័យនៃគ្រោះមហន្តរាយដោយធម្មជាតិ និងដោយមនុស្ស

ឃ- ចាត់ការជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងសប្បុរសជន ដើម្បីអនុវត្តគោលនយោបាយជាតិ នៃការគ្រប់គ្រងគ្រោះមហន្តរាយ ដោយដូចជាការត្រៀមបង្ការ ការសំរាល ការត្រៀមរៀបចំ ដើម្បីទប់ទល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស

ង- ធ្វើការទំនាក់ទំនង សំរបសំរួលកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការផ្តល់ព័ត៌មានអោយគ្នាទៅវិញទៅមកអំពីស្ថានភាព និងស្ថានការណ៍ គ្រោះមហន្តរាយ សំដៅកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ

ច- ធ្វើការសំរបសំរួលជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងសប្បុរសជនក្នុងស្រុក ដើម្បីកៀរគរ ស្វែងរកជំនួយសំរាប់ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញរាល់ការខូចខាតដោយគ្រោះមហន្តរាយ ។

**មាត្រា ២.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស.០៤០៨.២៣៧

លេខៈ ១៩៤ .

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ... ឆ្នាំ២០០៤

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/៧៣៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទិ ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទិ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-**

បង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ ហៅកាត់ " **គ.ជ.ប.អ** "។

**មាត្រា ២ .-**

**គ.ជ.ប.អ** មានតួនាទីជាជំនួយការក្នុងការត្រួតពិនិត្យការរៀបចំនិងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានាសំរាប់ប្រជាជន។

**មាត្រា ៣ .-**

**គ.ជ.ប.អ** មានគោលដៅនាំទៅរកការផ្លាស់ប្តូរក្នុងទិន្នាការប្រជាជន ដើម្បីអោយទំហំសមាសភាព និងរបាយប្រជាជនសមស្របជាមួយនឹងតំរូវការនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព សំរាប់កាត់បន្ថយភាពក្រីក្រ និង ការធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវិតរស់នៅរបស់ប្រជាជនកម្ពុជា។

**មាត្រា ៤ .-**

សមាសភាពថ្នាក់ដឹកនាំនៃ **គ.ជ.ប.អ** រួមមានដូចខាងក្រោម ÷

| | |
|---|---|
| - ឥស្សរៈជនមួយរូប | ជាប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ពីររូប | ជាអនុប្រធាន |
| - ឥស្សរៈជនមួយរូប | ជាអនុប្រធាន |
| - ឥស្សរៈជនមួយរូប | ជាអនុប្រធានប្រចាំការ |
| - តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| - តំណាង ក្រសួងផែនការ | ជាសមាជិក |
| - តំណាង ក្រសួងបរិស្ថាន | ជាសមាជិក |
| - តំណាង ក្រសួងសុខាភិបាល | ជាសមាជិក |
| - តំណាង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ជាសមាជិក |
| - តំណាង ក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| - តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| - តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| - តំណាង ក្រសួងកិច្ចការនារី | ជាសមាជិក |
| - តំណាង ក្រសួងអភិវឌ្ឍជនបទ | ជាសមាជិក |
| - តំណាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| - តំណាង ក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |

**មាត្រា ៥ .-**

**គ.ជ.ប.អ** មានបេសកកម្មដូចតទៅ ÷

- ធានាកិច្ចសហការ សំរបសំរួល ដ៏សមស្របក្នុងការអនុវត្ត គោលនយោបាយ និងកម្មវិធី ដែលទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ

- ត្រួតពិនិត្យតាមដាន និង វាយតំលៃពីគោលនយោបាយ និងកម្មវិធីទាំងឡាយ ដែលទាក់ទង នឹង សេវាកម្មពន្យារកំណើត សុខភាពបន្តពូជ សន្តិសុខស្បៀង ការអភិវឌ្ឍធនធានមនុស្ស យេនឌ័រ និងការអភិវឌ្ឍ បរិស្ថាន ការរៀបចំដែនដី ការបំលាស់ទីលំនៅ ជីវភាពរស់នៅ ការអភិវឌ្ឍប្រកបដោយចីរភាព កិច្ចការពារ និងលើកកំពស់សុខមាលភាព និងការចូលរួមចំណែករបស់ប្រជាជន និងគោលនយោបាយផ្សេងៗទៀត ដែលទាក់ទងនឹងប្រជាជន និងការអភិវឌ្ឍ ។

**មាត្រា ៦.-**

**គ.ជ.ប.អ** ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង មានភារកិច្ចដូចតទៅ ÷

- ស្រាវជ្រាវ និងផ្សព្វផ្សាយពត៌មាន ស្តីពីសេចក្តីត្រូវការ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងប្រជាជន ជូនទៅរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពនានា
- សំរបសំរួល និងធ្វើសហប្រតិបត្តិការជាមួយនឹងក្រសួងពាក់ព័ន្ធ តំណាងភ្នាក់ងារអង្គការសហប្រជាជាតិជាពិសេសជាមួយនឹងអង្គការមូលនិធិសហប្រជាជាតិសំរាប់ប្រជាជន(UNFPA) អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន និងតំណាងវិទ្យាស្ថានស្រាវជ្រាវ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ ដើម្បីធានានូវភាពរលូន និងភាពជាដៃគូក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល
- សំរបសំរួលជាមួយគណៈកម្មការនៃរដ្ឋសភា និងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងចូលរួមដឹកនាំសិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទជាតិនិងអន្តរជាតិ ដើម្បីជាជំនួយក្នុងការសំរេចគោលដៅ កម្មវិធីនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ចងក្រង និងផ្សព្វផ្សាយឯកសារគោលនយោបាយ ផែនការ កម្មវិធី គោលនយោបាយ និង សេចក្តីប្រកាស ដែលទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ
- ត្រួតពិនិត្យ និងកែសម្រួលគោលនយោបាយប្រជាជន និងយុទ្ធសាស្ត្រជាតិប្រជាជនអោយកាន់តែល្អប្រសើរ តាមការវិវត្តន៍ នៃសភាពការណ៍ក្នុងតំបន់ និងពិភពលោក
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងពត៌មានក្នុងការផ្សព្វផ្សាយនិងបញ្ចូលបញ្ហាប្រជាជននិងការអភិវឌ្ឍទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថាននានា
- ទទួលអនុវត្តការងារមួយចំនួនថែមទៀត ដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីប្រគល់ជូន

- ធ្វើរបាយការណ៍ ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារតាមកាលកំណត់អោយបានទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៧.-**

- **គ.ជ.ប.អ** មានអគ្គលេខាធិការដ្ឋានជាជំនួយការ និងមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប
- អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមានផ្នែកជំនាញមួយចំនួនតាមការចាំបាច់
- អគ្គលេខាធិការរង មានឋានៈស្មើ អគ្គនាយក
- ផ្នែកជំនាញត្រូវដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន
- អគ្គលេខាធិការដ្ឋានអាចបង្កើតក្រុមជំនាញនៅតាមខេត្ត-ក្រុង ។

**មាត្រា ៨.-**

- **គ.ជ.ប.អ** ធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធាន
- **គ.ជ.ប.អ** ត្រូវប្រជុំជាសាមញ្ញរៀងរាល់មួយត្រីមាសម្តង និងអាចប្រជុំជាវិសាមញ្ញតាមការចាំបាច់
- ប្រធានអាចអញ្ជើញ អ្នកមានសមត្ថកិច្ចផ្សេងៗ នៃតំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ផ្នែកឯកជន តំណាងវិទ្យាស្ថានស្រាវជ្រាវពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេស អ្នកផ្តល់ជំនួយ សង្គមស៊ីវិល អោយចូលមកបំភ្លឺ ចូលរួមកិច្ចប្រជុំការងារ រឺសិក្សាលើឯកសារពាក់ព័ន្ធ ។

**មាត្រា ៩.-**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ស្ថាប័ន **គ.ជ.ប.អ** នេះត្រូវកំនត់ដោយអនុក្រឹត្យ ។

**មាត្រា ១០.-**

**គ.ជ.ប.អ** មានប្រភពធនធានផ្តត់ផ្គង់ដោយថវិកាជាតិ ក្នុងកញ្ចប់ថវិកានៃទីស្តីការគណៈរដ្ឋមន្ត្រី និងដោយជំនួយពី ប្រភពផ្សេងៗ ។

**មាត្រា ១១ .-**

**គ.ជ.ប.អ** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងដំណើរការការងាររបស់ខ្លួន ។

**មាត្រា ១២ ៖**

ព្រះរាជក្រឹត្យលេខ នស / រកត / ០៨០១ / ២៧៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៣ ៖**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តន៍អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៤ ៖**

ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសំបទ្ទាប់**

**ប្រមុខរដ្ឋស្តីទី**

៣ រល. ០៤០៨. ២៣៨

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ ១៧៥ ចណ

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងឌី តាន់**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៣៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា

*********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញសេចក្តីសំរេចលេខ ៤២ ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានអក្សរកាត់ថា " អ ជ ទ ក " ។

**មាត្រា២ .-**

អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានសមាសភាពដូចតទៅ :

១-ឯកឧត្តម **វេង សេរីវុឌ្ឍ** ទេសរដ្ឋមន្ត្រី ប្រធាន

២-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ប៉ាណារ៉ា សេរីវុឌ្ឍ** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អនុប្រធាន

៣-ឯកឧត្តម **ឡាយ ព្រហស្ស** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អនុប្រធាន

៤-ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៥-ឯកឧត្តម **សេង លឹមនៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកប្រចាំការ

៦-ឯកឧត្តម **ត្រាំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៧-ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៨-ឯកឧត្តម **គង់ វិបុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៩-ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១០-ឯកឧត្តម **ច័ន្ទ តុងអ៊ីវ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១១-ឯកឧត្តម **ឆាន់ សាផាន** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១២-ឯកឧត្តម **នឹម ធុត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១៣-ឯកឧត្តម **ថាវ់ ដែន** រដ្ឋលេខាធិការក្រសួងពត៌មាន សមាជិក

១៤-ឯកឧត្តម **ពេជ្រ សោភ័ណ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៥-ឯកឧត្តម **ម៉ុន ណារិទ្ធ** ប្រធានអគ្គនាយក រគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា សមាជិក

១៦-ឯកឧត្តម **សយ សុខាន់** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

១៧-លោកឧត្តមសេនីយ៍ **យុន ឈុន្នី** ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

១៨-អគ្គលេខាធិការ " អជទក " សមាជិក

**មាត្រា៣ .-**

អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម :

-ជួយរាជរដ្ឋាភិបាល ក្នុងការរៀបចំកសាងគោលនយោបាយ យុទ្ធសាស្ត្រជាតិ ផែនការអភិវឌ្ឍន៍ ការត្រួតពិនិត្យ និងសម្របសម្រួលការងារអនុវត្ត លើការអភិវឌ្ឍវិស័យឧស្សាហកម្មទេសចរណ៍ជាតិ

-ត្រៀមការងារជូនរាជរដ្ឋាភិបាល ដើម្បីសំរេចលើគំរោងអភិវឌ្ឍន៍ ឬវិនិយោគនានា នៃវិស័យឧស្សាហកម្មទេសចរណ៍

-ដឹកនាំក្រសួងទេសចរណ៍ក្នុងការតាមដាន បញ្ជាក់ និងត្រួតពិនិត្យលទ្ធផល នៃការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រជាតិ ព្រមទាំងផែនការសកម្មភាពទាំងឡាយដែលទាក់ទងដល់កិច្ចអភិវឌ្ឍន៍វិស័យឧស្សាហកម្មទេសចរណ៍

-កំណត់គោលអាទិភាព សំរាប់កិច្ចអភិវឌ្ឍន៍វិស័យឧស្សាហកម្មទេសចរណ៍

-ទទួលបន្ទុករៀបចំ និងលើកគំរោងការងារ ផ្សព្វផ្សាយ និងទីផ្សារទេសចរណ៍ រួមទាំងព្រឹត្តការណ៍ទេសចរណ៍

-ទទួលបន្ទុករៀបចំ និងលើកគំរោងការងារសន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរណ៍

-សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ផ្នែកឯកជន និងសមាគមទាំងឡាយដែលប្រកបអាជីវកម្មវិស័យឧស្សាហកម្មទេសចរណ៍ លើការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព ដែលជាប់ទាក់ទងក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មទេសចរណ៍ ដោយឈរលើមូលដ្ឋាននៃផែនការអភិវឌ្ឍន៍ជាតិ

-សហការជាមួយអគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា ក្នុងការលើកគំរោងអភិវឌ្ឍវិស័យទេសចរណ៍ នៅតំបន់សៀមរាប អង្គរ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ឱ្យបានទៀងទាត់ ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤ ..**

អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានអគ្គលេខាធិការដ្ឋានជាជំនួយការ និងមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ដឹកនាំដោយអគ្គលេខាធិការមួយរូប ទទួលបន្ទុកកិច្ចការរដ្ឋបាល ថវិកា និងការរៀបចំគ្រប់គ្រងឯកសារទូទៅ

-អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមានផ្នែកជំនាញមួយចំនួនតាមការចាំបាច់

-អគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយក

-ប្រធានផ្នែកជំនាញ មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានមន្ត្រីមួយចំនួនជាជំនួយការ ។

**មាត្រា៥ ..**

អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ត្រូវធ្វើការប្រជុំសាមញ្ញរៀងរាល់មួយត្រីមាសម្តង ហើយអាចកោះប្រជុំជាវិសាមញ្ញតាមការចាំបាច់ និងតាមការអញ្ជើញរបស់ប្រធាន " អ ជ ទ ក " ។ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានសិទ្ធិទទួលមធ្យោបាយសំភារៈទេសចរណ៍ និងប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល គ្រឹះស្ថានឯកជននានា សំរាប់កិច្ចដំណើរការការងាររបស់ខ្លួន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៦ ..**

អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់សិទ្ធិកាន់កាប់ទីតាំងដីដែលមាន

## ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សរ.០០០៦៦៨ ចុះថ្ងៃទី ២៥-១-៩៦

*****

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៨៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១.** -

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក *Christian ROUANET-MEHOUAS* លេខាទី២ នៃស្ថានឯកអគ្គរដ្ឋទូត សាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ជាពិសេសជាមួយកងយោធពលខេមរភូមិន្ទ ។

**មាត្រា២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

A..103

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៨១.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

### សម្រេច

**មាត្រា១.** -

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន មន្ត្រីសង្ឃ និង ជូនសប្បុរសជន ដែលមានគុណបំណាច់ខ្ពស់ក្នុងការចូលរួមកសាង និង អភិវឌ្ឍន៍ វិស័យព្រះពុទ្ធសាសនា និង សង្គមជាតិ ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

១-សម្តេចព្រះពោធិវង្ស **នន្ទ ង៉ែត** សង្ឃនាយករងទី១ គណៈមហានិកាយ

២-មហាឧបាសក **ហ៊ុន នាង** ប្រធានកិត្តិយស វត្តបុទុមវតី រាជធានីភ្នំពេញ

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

-ព្រះញាណកោសល **សោរ ចន្ទថុល** ចៅអធិការវត្តលង្កា រាជធានីភ្នំពេញ

**មាត្រា២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច /
-ឯកសារ-កាលប្បវត្តិ

A105

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៨៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១.** -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **ខ្វាន់ ស៊ាង** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន អស់ចំនួន ៣១.០០០ ដុល្លារអាមេរិក ចូលរួមជួយកសាង និង អភិវឌ្ឍន៍ វិស័យព្រះពុទ្ធសាសនា និង សង្គមជាតិ ។

**មាត្រា២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញៈថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

A. 104

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៤៩ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបន្តការងាររបស់គណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវយកទៅតាំងពិពណ៌នៅសាធារណៈរដ្ឋកូរ៉េ ប្រទេសជប៉ុន សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ និង ប្រទេសអេស្ប៉ាញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបន្តការងាររបស់គណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យលើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវបានខ្ចីយកទៅតាំងពិពណ៌ នៅសាធារណៈរដ្ឋកូរ៉េ ប្រទេសជប៉ុន សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងប្រទេសអេស្ប៉ាញ ដែលមានសមាសភាព ដូចតទៅ :

១- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាព្រះប្រធាន

២- ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៣- ឯកឧត្តម សេង លិមនៅរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤- ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

៥- ឯកឧត្តម ជុំ ភឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៧- ឯកឧត្តម យឹម សារិទ្ធ រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៨- ឯកឧត្តម ទិប ចាន់ថារ៉ា អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩- ឯកឧត្តម ង៉ី តាយី អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០- ឯកឧត្តម អ៊ីវ ខេង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកអចិន្ត្រៃយ៍ និងជា អគ្គលេខាធិការគណៈកម្មការ

១១- ឯកឧត្តម ស៊ុម ស្នូង អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

១២- ឯកឧត្តម បណ្ឌិត ប៉ែន បារេត ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣- លោកជំទាវ តាន់ ធាទី អគ្គលេខាធិការគណៈកម្មការជាតិយូណេស្កូ សមាជិក

១៤- ឯកឧត្តម បណ្ឌិត ក្រាញ់ ច័យណាភី ទូធី អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៥- ឯកឧត្តម រស់ បូរ៉ាត អគ្គនាយករងអាជ្ញាធរអប្សរា ទទួលបន្ទុកការងាររមណីយដ្ឋាន និងបុរាណវិទ្យា សមាជិក

១៦- ឯកឧត្តម ឌុយ គឿន សាកលវិទ្យាធិការ សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សមាជិក

១៧- ឯកឧត្តម ខិម វិសិដ្ឋ ប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៨- លោក ស្ទួស យ៉ារ៉ា អគ្គលេខាធិការ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា សមាជិក

១៩- លោក ពេជ កែវ អគ្គនាយករងបច្ចេកទេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

២០- លោក អ៊ូង វន ប្រធាននាយកដ្ឋានបិតិកភណ្ឌវប្បធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសមាជិក

២១- លោក យុន សាម៉េន ប្រធាននាយកដ្ឋាន សារមន្ទីរ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្ប សមាជិក

២២- លោក ចង់ អ្នក ប្រធាននាយកដ្ឋាន សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងសិទ្ធមនុស្ស ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

២៣- លោក ឡាយ ណាវុឌ្ឍ អនុប្រធាននាយកដ្ឋានស្ថាបនា ក្រសួងមហាផ្ទៃ សមាជិក

២៤- លោក សុក សារ៉េត អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ ២.-**

គណៈកម្មការនេះមានភារៈកិច្ចធ្វើការទំនាក់ទំនង នឹងក្រសួងពាក់ព័ន្ធនានា និងសាធារណៈរដ្ឋកូរ៉េ ប្រទេសជប៉ុន សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងប្រទេសអេស្ប៉ាញ ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យលើវត្ថុបុរាណសិល្បៈខ្មែរ សំរាប់ទៅតាំងពិពណ៌ នៅតាមប្រទេសនិមួយៗ។

**ប្រការ ៣.—**

អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទេសចរណ៍កម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាលេខាធិការ របស់អគ្គលេខាធិការ ។

**ប្រការ ៤.—**

សេចក្តីសំរេចនេះ គ្របដណ្តប់លើសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល

- លេខ ៥៣ ស.ស.រ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីវាយតម្លៃ និងត្រួតពិនិត្យវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន TOEI ប្រទេសជប៉ុន ខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុន រយៈពេលមួយឆ្នាំ ចាប់ពីខែ កញ្ញា ឆ្នាំ ២០០៤
- លេខ ០៥ ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន TOEI ជប៉ុន ខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុន រយៈពេល ១៤ ខែ ចាប់ពីខែ មិថុនា ឆ្នាំ ២០០៥ ដល់ខែ កក្កដា ឆ្នាំ ២០០៦ និងសារមន្ទីរសិល្បៈ និងមហោស្រពពិពណ៌ នៃសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ ខ្ចីយកទៅតាំងពិពណ៌នៅទីក្រុងបោន សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ រយៈពេល ៦ ខែ ឆ្នាំ ២០០៦-២០០៧
- លេខ ១៦ ស.ស.រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការបន្ថែមភារៈកិច្ច និងសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវខ្ចីយកទៅតាំងពិពណ៌ នៅប្រទេស ជប៉ុន សាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសាធារណៈរដ្ឋកូរ៉េ

**ប្រការ ៥.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាជ្ញាធរអប្សរា អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ ដែលបានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា . ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤០ សសរ...

## សេចក្តីសំរេច
## ស្តីពីការផ្លាស់ប្តូរប្រធានគណៈកម្មការចំរុះ ចុះបង្រ្កាបបទល្មើស ព្រៃឈើ នៅតំបន់កន្ទុយនាគ ក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី

៙៙★៙៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩១/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

-បានឃើញសេចក្តីសំរេច លេខ ៤១ សសរ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការចំរុះ ចុះបង្រ្កាបបទល្មើសព្រៃឈើ នៅតំបន់កន្ទុយនាគ ក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១ .-**

ប្រគល់ភារកិច្ចជូន ឯកឧត្តម **យិន គឹមស៊ាន** រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាប្រធានគណៈកម្មការចំរុះ ចុះបង្រ្កាបបទល្មើសព្រៃឈើ នៅតំបន់កន្ទុយនាគ ក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី ជំនួសឯកឧត្តម **ឆាន់ សាផាន** ដែលត្រូវបានទៅទទួលភារកិច្ចថ្មី ។

**ប្រការ២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ អភិបាលខេត្តរតនៈគិរី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យបានសម្រេចចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ២
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១ អនក្រ

## សេចក្តីសំរេច

## ស្តីពី

## ការកែតម្រូវសមាសភាពគណៈកម្មាធិការគ្រប់គ្រង

## អាកាសយានដ្ឋានអន្តរជាតិ

----------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ១៥សសរ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ

## សម្រេច

**ប្រការ ១.-**

ប្រការ១ នៃសេចក្តីសំរេចលេខ ១៥សសរ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ត្រូវបានកែតម្រូវដូចខាងក្រោម :

**ប្រការ ១ថ្មី.-**

ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដែលមានសមាសភាពដូចតទៅ :

- ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- ឯកឧត្តម **ព្រំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការរង នៃអគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ អនុប្រធាន
- ឯកឧត្តម **កែវ សាផល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធានប្រចាំការ
- ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- ឯកឧត្តម **ផាន់ ខួន** អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ សមាជិក
- ឯកឧត្តម **ហែម ក្រាញ់ តូនី** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **មាស គីមសុវ៉ារ៉ី** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ឯកឧត្តម **សូ ម៉ារ៉ា** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
- ឯកឧត្តម **ម៉ៅ ថូរ៉ា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

- ឯកឧត្តម **ម៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **ពៅ សាមី** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- ឯកឧត្តម **ជា សុខុម** អគ្គលេខាធិការរងទី១នៃអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
- ឯកឧត្តមឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- ឯកឧត្តមឧត្តមសេនីយ៍ **សឹម សំណាង** មេបញ្ជាការកងទ័ពជើងអាកាស សមាជិក
- ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ សមាជិក
- លោក **អ៊ុំ អឿន** អភិបាលរងទី១ខេត្តសៀមរាប សមាជិក
- លោក **ម៉ិុន នី** ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងជាប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិក
- លោក **ម៉ិុន វដ្ឋា** ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងជាប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិសៀមរាប សមាជិក

**ប្រការ ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ថ្មី ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ...៨២...សសរ

# សេចក្តីសម្រេច
## ស្តីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយ
## បញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការ សំរាប់ដោះស្រាយកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន
២- ឯកឧត្តម **ញៀម ម៉ុន ជីន** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន
៣- ឯកឧត្តម **ហុក ឡុងឌី** អគ្គស្នងការ នគរបាលជាតិ អនុប្រធាន
៤- ឯកឧត្តមអភិបាលក្រុងភ្នំពេញ អនុប្រធាន

| | | | |
|---|---|---|---|
| ៥- | ឯកឧត្តម **ម៉ុក ឌន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- | ឯកឧត្តម **មិន ឃិន** | រដ្ឋលេខាធិការក្រសួងធម្មការ និង កិច្ចការសាសនា | សមាជិក |
| ៧- | ឯកឧត្តម **មល់ រឿប** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៨- | ឯកឧត្តម **ខួត រ៉ាន់ឌី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |
| ៩- | ឯកឧត្តម **គីម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- | ឯកឧត្តម **ម៉ិន សម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១- | ឯកឧត្តម **ស្វាយ ស៊ីថា** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២- | ឯកឧត្តម **អ៊ុំ មាន** | អនុរដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣- | ឯកឧត្តម **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៤- | ឯកឧត្តម អភិបាលខេត្តរងខេត្តកណ្តាល | | សមាជិក |
| ១៥- | ឯកឧត្តម **ជុំ ហាក់** | មេបញ្ជាការរងកងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ | សមាជិក |

**ប្រការ ២:** គណៈកម្មការនេះ មានភារកិច្ច :

- តាមដាន ទប់ស្កាត់ និង លើកវិធានការដោះស្រាយអោយមានប្រសិទ្ធភាព នូវរាល់បញ្ហាកូដកម្ម បាតុកម្ម ដែលកើតមានឡើងនៅតាមគ្រប់មុខសញ្ញា ។
- ធ្វើរបាយការណ៍ អំពីវិធានការដំណោះស្រាយ និង លទ្ធផលនៃការងារខាងលើ ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣:** គណៈកម្មការនេះ ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ ។

**ប្រការ ៤:** សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ឯកឧត្តមប្រធាន។ គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សំរាប់សំរួលការងារ។

**ប្រការ ៥:** ថវិកាចំណាយប្រើប្រាស់របស់គណៈកម្មការនេះ ត្រូវបញ្ចូលបន្ថែម ក្នុងខ្ទង់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**ប្រការ ៦:** បទបញ្ញត្តិទាំងឡាយណា ផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និង ឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៥៣...សសរ

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមសន្និសីទអន្តរជាតិលើកទី ៣ នៃគណបក្សនយោបាយនៅអាស៊ី និងបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៤ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៧...សរណន

# សារាចរណែនាំ
# ស្តីពី
# ការប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា

ដោយអនុវត្តតាមផែនការជាតិនៃការអប់រំសំរាប់ទាំងអស់គ្នា ដែលប្រកាសផ្សព្វផ្សាយអនុវត្តនាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣ និងផ្អែកលើព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការកំនត់យកថ្ងៃទី ៨ ខែ កញ្ញា រៀងរាល់ឆ្នាំ ជាទិវាអក្ខរកម្មជាតិ និងដើម្បីបំផុស ឃោសនា ផ្សព្វផ្សាយ បង្កើនការយកចិត្តទុកដាក់ជួយឧបត្ថម្ភគាំទ្រ និង លើកទឹកចិត្តដល់ចលនាអក្ខរកម្មអោយបានខ្លាំងក្លាថែមទៀតនោះ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង អោយរៀបចំប្រារព្ធទិវាអក្ខរកម្មជាតិ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៤ ក្រោមប្រធានបទ **"អក្ខរកម្ម ជាគន្លឹះនៃការអភិវឌ្ឍ"** ដូចខាងក្រោម :

១. ក្រសួងអប់រំ យុវជន និង កីឡា ត្រូវរៀបចំពិធីមីទ្ទិញថ្នាក់ជាតិ ជានិមិត្តរូបនៅតាមខេត្ត ក្រុងណាមួយ ដើម្បីផ្សព្វផ្សាយលទ្ធផលអក្ខរកម្មឆ្នាំកន្លងមក និង ប្រកាសអំពីផែនការនៃការអនុវត្តផែនការជាតិអប់រំសំរាប់ទាំងអស់គ្នានៅទូទាំងប្រទេសទៅថ្ងៃមុខ។

២. ក្រសួង មន្ទីរ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចាត់ចែងរៀបចំបិទបដា ពាក្យស្លោកដូចជូនភ្ជាប់នៅតាមអង្គភាពរដ្ឋ ទីប្រជុំជន ដងផ្លូវសាធារណៈ ចាប់ពីថ្ងៃទី ៧ ដល់ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០៤។

៣. ក្រសួងធម្មការ និង កិច្ចការសាសនា ត្រូវទូលសុំព្រះសង្ឃ បព្វជិតសាសនាដទៃទៀត និង ណែនាំគណៈកម្មការវត្តគ្រប់ជាន់ថ្នាក់ និង សាវ័ក អោយចូលរួមដល់ការងារអក្ខរកម្ម។

៤. ក្រសួងព័ត៌មានត្រូវរៀបចំជាកម្មវិធីសិល្បៈ បទអត្ថាធិប្បាយ បទយកការណ៍ ស្តីពីការងារអប់រំក្រៅប្រព័ន្ធនៅកម្ពុជា ផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍។

៥. អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវចាត់ចែងរៀបចំ :

ក-ធ្វើមីទ្ទិញ ឬ ប្រជុំហែក្បួនដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងការឧបត្ថម្ភគាំទ្រ និង លើកទឹកចិត្តដល់ចលនាអក្ខរកម្ម ដែលជាកូនសោ ក្នុងការអភិវឌ្ឍខ្លួនឯង គ្រួសារ សហគមន៍ និង ប្រទេសជាតិទាំងមូល។

ខ-សហការជាមួយបណ្ដាអង្គការនានា ដែលធ្វើសកម្មភាពផ្នែកអប់រំក្រៅប្រព័ន្ធ ដើម្បីរៀបចំជាពិពណ៌ បង្ហាញ អំពីសកម្មភាព និង លទ្ធផលនៃការងារអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំកន្លងមក ។

គ- បំផុសចលនា និង ធ្វើការប្រឡងជ្រើសរើសសិស្សអក្ខរកម្មពូកែតាមលក្ខខ័ណ្ឌដូចខាងក្រោម :

-ចំពោះទីកន្លែងដែលមានថ្នាក់អក្ខរកម្ម ត្រូវចាត់ចែងរៀបចំប្រឡង ហើយបេក្ខជនដែលទទួលបានពិន្ទុល្អ ក្នុងការប្រឡងនឹងត្រូវបានជូនរង្វាន់លើកទឹកចិត្តតាមលទ្ធភាពរបស់ខេត្ត ក្រុង និង មូលដ្ឋានទីមួយៗ ។

-ចំពោះទីកន្លែងដែលពុំមានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់ចែងរៀបចំអោយមន្ត្រីជំនាញចុះឃោសនាអំពី សារៈសំខាន់នៃការរៀនសូត្រ ដែលជាមូលដ្ឋានគ្រឹះនៃការអប់រំ ។

ឃ-ចាត់ចែងឃោសនា អំពាវនាវដល់អង្គការជាតិ អង្គការអន្តរជាតិ ផ្នែកឯកជន និង សាធារណជន ទូទៅអោយ ចូលរួមជួយគាំទ្រដល់សកម្មភាពទិវានេះក្នុងតំបន់រៀងៗខ្លួន ។

៦. គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នានៅគ្រប់លំដាប់ថ្នាក់ ត្រូវប្រជុំរៀនសូត្រអំពីគោលនយោបាយនៃការងារ អប់រំក្រៅប្រព័ន្ធ និង ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ព្រមទាំងបូកសរុបលទ្ធផលនៃការងារអប់រំក្រៅ ប្រព័ន្ធតាមសភាពជាក់ស្ដែង តាមឋានានុក្រមនីមួយៗ ។

៧. អង្គការជាតិ អង្គការអន្តរជាតិ ផ្នែកឯកជន និង សាធារណជនសូមចូលរួម ជួយសហការគាំទ្រទិវានេះ អោយបានខ្លាំងក្លានៅតាមទីកន្លែង និង តាមលទ្ធភាពរបស់ខ្លួន ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្ដម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាត្រូវផ្សព្វផ្សាយ និង រៀបចំណែនាំព្រមទាំងអនុវត្តន៍សារាចរនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ រួចហើយធ្វើរបាយការណ៍ស្ដីពីលទ្ធផលនៃការរៀបចំពិធីនេះ ផ្ញើមកក្រសួងអប់រំ យុវជន និង កីឡា ដើម្បីបូកសរុបជូនគណៈរដ្ឋមន្ត្រីអោយបានមុនដំណាច់ខែ កញ្ញា ឆ្នាំ ២០០៤ ។

រាជធានីភ្នំពេញ, [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័ននានា
-គ្រប់សាលាខេត្ត ក្រុង
-កាលប្បវត្តិ -ឯកសារ

## ពាក្យស្លោក

១. ជយោ ! ព្រះរាជាណាចក្រកម្ពុជា
២. ជាតិ សាសនា ព្រះមហាក្សត្រ
៣. អបអរសាទរទិវាអក្ខរកម្មជាតិ ៨ កញ្ញា
៤. រៀនហើយ រៀនទៀត រៀនពេញមួយជីវិត
៥. អប់រំសំរាប់ទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ
៦. រៀនដើម្បីអភិវឌ្ឍខ្លួនឯង គ្រួសារ និងសង្គមជាតិ
៧. អក្ខរកម្មជាពន្លឺនៃសុភមង្គល
៨. អក្ខរកម្ម គឺជាគន្លឹះនៃការអភិវឌ្ឍន៍
៩. អក្ខរកម្មរួមចំណែកកាត់បន្ថយភាពក្រីក្រ
១០. អក្ខរកម្មទប់ស្កាត់អេដស៍
១១. អក្ខរកម្មទប់ស្កាត់ការកេងប្រវ័ញ្ចពលកម្មកុមារ
១២. អក្ខរកម្មទប់ស្កាត់ការប្រើគ្រឿងញៀន
១៣. អក្ខរកម្ម ជាមធ្យោបាយបំបាត់អំពើហឹង្សា
១៤. មានអក្ខរកម្ម មានចំណេះដឹង មានការអភិវឌ្ឍន៍
១៥. អក្ខរកម្មជាគន្លឹះសំរេចការអប់រំសំរាប់ទាំងអស់គ្នា
១៦. អក្ខរកម្មជាមូលដ្ឋាននៃការសិក្សាពេញមួយជីវិត
១៧. អក្ខរកម្ម គឺជាគ្រឹះនៃចំណេះដឹង
១៨. អក្ខរកម្មជាគ្រឹះនៃការអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០៩ សរណន**

## សារាចរណែនាំ

## ស្តីពី

## ការពង្រឹងវិធានការការពារសន្តិសុខ និងសុវត្ថិភាព ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ

~~~~~~~~

កន្លងមកថ្មីៗនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា នៅតំបន់ទេសចរណ៍មួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសនៅរាជធានីភ្នំពេញ និងនៅទីក្រុងព្រះសីហនុ បានកើតឡើងនូវសកម្មភាពអសកម្មដែលបង្កឡើងដោយជនខិលខូចមួយចំនួនតូច តែងតែដើរលួច ឆក់ ប្លន់ទ្រព្យសម្បត្តិ ឬចាប់រំលោភ បង្កឱ្យមានរបួសស្នាមលើរូបរាងកាយរបស់អ្នកទេសចរជាតិ និងអន្តរជាតិ។ ទន្ទឹមនេះ ការលក់ដូរវត្ថុអនុស្សាវរីយ៍ អនាម័យម្ហូបអាហារតាមភោជនីយដ្ឋាននានា និងគ្រោះថ្នាក់ផ្សេងៗចំពោះភ្ញៀវទេសចរក៏នៅមានជួបបញ្ហាអសកម្មខ្លះៗនៅឡើយដែរ ។

ដើម្បីបន្តពង្រឹងឱ្យបាននូវការជឿទុកចិត្ត និងភាពកក់ក្តៅរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចំពោះសន្តិសុខ និងសុវត្ថិភាពក្នុងដំណើរទស្សនកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១-ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ សហការជាមួយអាជ្ញាធរដែនដីខេត្ត-ក្រុង ត្រូវចាត់វិធានការចាំបាច់បន្ទាន់នានា ដើម្បីពង្រឹងកិច្ចការពារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសតំបន់ទេសចរណ៍សំខាន់ៗ ជាអាទិ៍ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ក្រុងព្រះសីហនុ ក្រុងកែប តំបន់ភូមិភាគឦសានជាដើម និងតំបន់គោលដៅទេសចរណ៍ដាច់ស្រយាលនានា សំដៅបញ្ចៀសនូវបាតុភាពលួច ឆក់ ប្លន់ ពីសំណាក់ជនខិលខូចមួយចំនួនតូច និងបាតុភាព អសកម្មខ្លះៗចំពោះភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដូចរយៈពេលកន្លងមក ។
~~~~~~~~

២-ក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំជាបន្ទាន់ដល់ក្រុមហ៊ុន សណ្ឋាគារ ម្ចាស់ផ្ទះសំណាក់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យពង្រឹងការងារចុះបញ្ជីឈ្មោះ អត្តសញ្ញាណភ្ញៀវជាតិ និងអន្តរជាតិ ដែលចេញ ចូល ស្នាក់នៅតាមសណ្ឋាគារ និងផ្ទះសំណាក់ឱ្យបានម៉ត់ចត់បំផុត ព្រមទាំងត្រូវឱ្យធ្វើការខិតខំបំពាក់ឧបករណ៍កាមេរ៉ាត្រួតពិនិត្យសន្តិសុខថែមទៀតផង។

គ្រប់សណ្ឋាគារ និងផ្ទះសំណាក់ ត្រូវចាត់ចែងរៀបចំឱ្យមានកងរក្សាសន្តិសុខយាមប្រចាំការជាអចិន្ត្រៃយ៍ ដើម្បីត្រួតពិនិត្យតាមដានលើរាល់សកម្មភាពរបស់ជនខិលខូច ដែលមានបំណងអាក្រក់ធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ភ្ញៀវទេសចរ។

៣-ក្រសួងទេសចរណ៍ ត្រូវសហការជាមួយធនាគារជាតិនៃកម្ពុជា និងត្រូវមានវិធានការត្រួតពិនិត្យឱ្យបានម៉ត់ចត់ដល់គុណភាពវត្ថុមានតម្លៃទាំងឡាយមុននឹងដាក់លក់ជូនភ្ញៀវ ។ ក្នុងករណីមានភស្តុតាងច្បាស់លាស់ ម្ចាស់ហាងលក់ដូរវត្ថុអនុស្សាវរីយ៍ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ត្រូវមានវិធានការពង្រឹងការគ្រប់គ្រង រាល់មធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរឱ្យបានម៉ត់ចត់ រាប់ទាំងមធ្យោបាយដឹកជញ្ជូនសាមញ្ញ និងបូរាណ ម៉ូតូឌុប ក្នុងការដឹកជញ្ជូនភ្ញៀវទេសចរ។

ត្រូវបង្កើនការដឹកនាំ និងគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរដែលជាតួអង្គយ៉ាងសំខាន់ ក្នុងការរួមចំណែកការពារកិត្យានុភាព និងប្រវត្តិសាស្ត្ររបស់ជាតិ និងកិច្ចការពារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរផងដែរ។

៤-ក្រសួងសុខាភិបាល ត្រូវត្រៀមលក្ខណៈរថយន្តពេទ្យចល័ត ដើម្បីជួយសង្គ្រោះភ្ញៀវទេសចរដែលមានគ្រោះថ្នាក់ជាបន្ទាន់ ដោយប្រចាំការជាអចិន្ត្រៃយ៍តាមគោលដៅទេសចរណ៍នានាឱ្យបានច្រើនកន្លែងតាមដែលអាចធ្វើទៅបាន។

ត្រូវមានវិធានការត្រួតពិនិត្យអនាម័យម្ហូបអាហារជាទូទៅ ពិសេសនៅតាមភោជនីយដ្ឋានដែលមានប្រជាប្រិយចំពោះភ្ញៀវទេសចរ។

៥-អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ត្រូវធ្វើសន្និបាតបូកសរុប វាយតម្លៃ និងលើកទិសដៅផែនការសំរាប់កិច្ចការពារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរឱ្យបានល្អ ហើយបន្ទាប់មកអាជ្ញាធរខេត្ត ក្រុង ត្រូវសហការ

ជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើការប្រជុំបូកសរុប វាយតម្លៃ និងលើកទិសដៅផែនការការពារសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវឱ្យបានល្អនៅតាមគោលដៅទេសចរណ៍នានាក្នុងមូលដ្ឋានខេត្ត ក្រុងសាមី ។

៦-ក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ត្រូវសហការជាមួយក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីលើកវិធានការរួមចំណែកក្នុងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យបានកាន់តែល្អប្រសើរថែមទៀត ដើម្បីបង្កើនជំនឿទុកចិត្តរបស់វិនិយោគិន អង្គការជាតិ និងអន្តរជាតិ ស្ថានទូត និងស្ថានតំណាងនានា ប្រចាំព្រះរាជាណាចក្រកម្ពុជា ជាពិសេសភ្ញៀវទេសចរជាតិ និងអន្តរជាតិ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងទេសចរណ៍ ក្រសួងព័ត៌មាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីខេត្ត ក្រុង ត្រូវធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តឱ្យទទួលបានលទ្ធផលជាវិជ្ជមាន ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គ្រប់ក្រសួង ស្ថាប័ន
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No ១៦៥ MOC / M 2004

# ប្រកាស
## ស្តីពីការបង្កើតគណកម្មាការរៀបចំការបោះឆ្នោតជ្រើសរើស សមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្ត-ក្រុង

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
-បានឃើញព្រះរាជក្រមលេខ នស/រកស/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក, ២៣ អនក្រ.បក, ២៤ អនក្រ.បក , ២៥ អនក្រ.បក, ២៦ អនក្រ.បក និង ២៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តកំពង់ចាម, បាត់ដំបង, បន្ទាយមានជ័យ, កោះកុង, សៀមរាប និងក្រុងសីហនុ
-យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មាការ រៀបចំការបោះឆ្នោតជ្រើសរើស សមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្ត-ក្រុង ដែលមានសមាភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាប្រធាន |
| ២-អ្នកឧកញ៉ា **សុខ គង់** | ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ | ជាអនុប្រធាន |

៣-លោក **សម សម្បត្តិ** អគ្គនាយករងបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម ជាសមាជិក

៤-លោក **ច្រាត់ នគ** ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម ជាសមាជិក

៥-លោក ឧកញ៉ា **ឈាង សុធី** អគ្គនាយកសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ជាសមាជិក

៦-លោក លោកស្រី ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ជាសមាជិក

៧-លោក **ហ៊ីម ហៀន** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការ

៨-លោក **ឌន ទិះ** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសនៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការ

**ប្រការ ២:** គណកម្មការនេះ មានភារកិច្ចធ្វើសបប្រតិបត្តិការ ជាមួយគណកម្មការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម នៅតាមខេត្ត-ក្រុងនីមួយៗ ក្នុងការចុះបញ្ជីអ្នកបោះឆ្នោត ចុះបញ្ជីបេក្ខជនឈរឈ្មោះ និងរៀបចំការបោះឆ្នោតទៅតាមខ្លឹមសារទាំងឡាយ ដែលបានចែងអំពីភារកិច្ចរបស់គណកម្មការនៅក្នុងជំពូក២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃ ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ។

**ប្រការ ៣:** បទបញ្ញត្តិទាំងឡាយ ដែលមានន័យផ្ទុយពីប្រការនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤:** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយិកាខុទ្ទកាល័យ សភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាក្រុងភ្នំពេញ
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២៧១ ប្រក.កសក

# ប្រកាស
## ស្តីពីការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់ របស់សមត្ថកិច្ចភូតគាមអនាម័យ

.......

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និង សេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ១៥អនក្រ.បកចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** បង្កើត និង កំណត់ ជាបណ្តោះអាសន្ន នូវឯកសណ្ឋាន និង សញ្ញាសម្គាល់សម្រាប់ប្រើប្រាស់ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យភូតគាមអនាម័យ ឬ ចូលរួមក្នុងពិធីផ្លូវការផ្សេងៗ។

**ប្រការ ២ :** ឯកសណ្ឋានសម្រាប់សមត្ថកិច្ចភូតគាមអនាម័យក្នុងនេះមានខោ-អាវ នឹងមួកត្រូវផលិតដោយសាច់ក្រណាត់តេហ្គាលខ្សែនពណ៌ស្លែចាស់ (សណ្តែកបាយ) ត្រូវកំណត់តាមតួនាទី នឹង ឋានៈ ដូចតទៅ :

**ក-ខោជើងវែង** ចំនួនពីរ ចង្កេះដេរតថ្មេរបង្កប់ជីបភ្លឺខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់គម្របរាងស្លឹកពោធិ៍ នឹង ហោប៉ៅពីរទៀតនៅ ចំហៀងដេរបង្កប់តាមថ្នេរ ។

**ខ-អាវមានពីរថ្នាក់:**

***-ថ្នាក់ដឹកនាំនាយកដ្ឋាននឹងការិយាល័យ :***

អាវដៃខ្លី ចំនួនពីរ កបើក ប៉ូលស្នា ផែកខ្នង មានហោប៉ៅបួន ហោប៉ៅពីរខាងលើដេរបត់ផ្នត់កណ្តាលគម្របរាងស្លឹកពោធិ៍ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្តាល គម្របរាងចតុកោណកែង ឡេវមានរូបព្រះសង្ហារពណ៌មាស ។

***-ថ្នាក់មន្ត្រីនឹងភ្នាក់ងារ :***

អាវដៃវែងមួយ អាវដៃខ្លីមួយ កឌុប ចោះឡេវចុងក ប៉ូលស្នា ហោប៉ៅពីរដេរបត់ផ្នត់កណ្តាលគម្របរាងស្លឹកពោធិ៍ កាត់ស្រុងជើងត្រង់ដាក់ក្នុងខោ ។

**គ-មួកកាស្កេតមានបួនថ្នាក់:**

***-ថ្នាក់ដឹកនាំនាយកដ្ឋាន :*** លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសប្រាំមួយទងពណ៌មាសទម្រង់ស្លែងក្របីចុងសងខាងដល់ជើងមួក ។ នៅលើកណ្តាប់វណ្ណផ្នែកខាងមុខចំកណ្តាលរចនាដោយបាច់ផ្កាភ្ញីទេស និង អមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទំហំទទឹង ២០មិល្លីម៉ែត្រ ។

***-ថ្នាក់ការិយាល័យ :*** លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសបួនទងពណ៌មាសទម្រង់ស្លែងក្របី ចុងសងខាងចន្លោះពីជើងមួក២០មិល្លីម៉ែត្រ ។

***-ថ្នាក់មន្ត្រីជាប្រធានស្នាក់ការ :*** លើជាយក្បាំងពណ៌ខ្មៅរចនាដោយបាច់ផ្កាភ្ញីទេសនៅចំកណ្តាល និង អមដោយក្បាច់សន្លឹកភ្ញីទេសពីរទងពណ៌មាសទម្រង់ស្លែងក្របីចុងសងខាងចន្លោះពីជើងមួក៤០មិល្លីម៉ែត្រ ។

***-ថ្នាក់មន្ត្រីនឹងភ្នាក់ងារ :*** លើជាយក្បាំងពណ៌ខ្មៅមានវិណ្ឌទំហំ០៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធវង់ដល់ជើងមួក ។

**ឃ-ស្បែកជើងឃ្មុបពណ៌ខ្មៅ កខ្មី ស្រោមជើងពណ៌ខ្មៅ ។**

**ង - ខ្សែក្រវ៉ាត់ ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ។**

**ប្រការ ៣ :** ស្លាកសញ្ញាសម្គាល់សមត្ថកិច្ចភូតគាមអនាម័យត្រូវបានកំណត់សម្គាល់ដូចខាងក្រោម សម្រាប់ពាក់លើចុងកអាវឆ្វេង-ស្តាំ ព្យួរលើឡេវគម្របហោប៉ៅឆ្វេងស្តាំ សម្រាប់សម្គាល់ឈ្មោះមន្ត្រីពាក់លើគម្របហោប៉ៅអាវខាងស្តាំ សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ ដូចខាងក្រោម :

**ក. ស្លាកសញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវឆ្វេង-ស្តាំ** : ធ្វើពីលោហធាតុដែលមានរាងមូលជារង្វង់គោលដែលមានអង្កត់ផ្ចិត៣០មិល្លីម៉ែត្រលំអដោយក្រឡាសរសៃជាខ្សែរយៈបណ្តោយចំនួន៣ ខ្សែរយៈទទឹងចំនួន៣ និង ខ្សែរង្វង់ជុំវិញជាខ្សែភ្លោះ។ ក្រឡាសរសៃជាខ្សែរយៈបណ្តោយ ខ្សែរយៈទទឹង និង ខ្សែរង្វង់ជុំខាងក្នុងមានទទឹង១មិល្លីម៉ែត្ររាងត្រីកោណផ្កាប់។ ខ្សែរង្វង់ព័ទ្ធខាងក្រៅមានទទឹង១.៥មិល្លីម៉ែត្រមានរាងជាចំណិតផ្តៅផុសផ្កាប់ ។ នៅចំកណ្តាលពីលើអឌ្ឍគោលផ្នែកខាងក្នុងខ្សែរង្វង់ផុសមានលំអដោយរូបភាពផុសនៃពស់មានពិសយកកន្ទុយរុំព័ទ្ធគល់កួរស្រូវមួយកួរ និង ស្លឹកស្រូវមួយសន្លឹក ដោយចំកោងខ្លួនពីឆ្វេងទៅស្តាំ យកក្បាលគ្របប្រក់ពីលើកួរស្រូវនិងស្លឹកស្រូវសម្រាប់ដាក់លើចុងកអាវស្តាំ និង ពីស្តាំទៅឆ្វេងសម្រាប់ដាក់លើចុងកអាវឆ្វេង ។

**ខ. ស្លាកសញ្ញាសម្គាល់សម្រាប់ព្យួរលើឡេវតម្រុបហោប៉ៅអាវស្តាំ** : មានរាងមូលប៉ោងធ្វើពីលោហធាតុមានអង្កត់ផ្ចិត៤៧មិល្លីម៉ែត្រ ភ្ជាប់ដោយខ្សែស្បែកពណ៌ឈាមជ្រូកត្រូវបានកំណត់ដូចខាងក្រោម :

- ***ផ្នែកគែមជុំវិញ :*** មានខ្សែពណ៌ក្រហមដែលមានទទឹង ០១មិល្លីម៉ែត្រព័ទ្ធជុំវិញ
- ***ផ្នែកខាងលើ :*** មានប្រាសាទកំពូលបីពណ៌មាស
- ***ផ្នែកសងខាង :*** មានបាច់កួរស្រូវនៅខាងស្តាំ និង បាច់នៃពោត និង កប្បាសនៅខាងឆ្វេង ដែលបាច់ទាំងពីរផ្តិតចេញជារង្វង់ស្នែងក្របី ដោយមានក្រណាត់ពណ៌ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា រុំព័ទ្ធខាងក្រោម និង រុំព័ទ្ធបាច់ទាំងពីរម្ខាងបីកំពង់
- ***ផ្នែកខាងក្រោម :*** អក្សរកាត់ "**កសក.រនជក**" ពណ៌សនៅលើក្រណាត់ពណ៌ក្រហមនៃទង់ជាតិ ដែលរុំព័ទ្ធជុំបាច់នៃផលិតផលកសិកម្ម និង នៅខាងក្រោមក្រណាត់ពណ៌ទង់ជាតិនោះមានរូបភាពចំណិតកង់ស្លឹពណ៌មាស ។
- ***ផ្នែកកណ្តាលស្លាក :*** ផ្ទៃជារង្វង់មូលមានពីរពណ៌ គឺពាក់កណ្តាលរង្វង់ខាងលើពណ៌ខៀវ និង ពាក់កណ្តាលរង្វង់ខាងក្រោមពណ៌បៃតងខ្ចី។ ផ្ទៃនៃពាក់កណ្តាលរង្វង់ទាំងពីរត្រូវបានគូសចែកដោយខ្សែសង្វារកាត់ផ្ចិតជាប្រាំ១ចំណែកស្មើគ្នា ដែលសណ្ឋានស្រដៀងគ្នាទៅនឹងសញ្ញាសម្គាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- ***នៅចំកណ្តាល :*** មានរូបពស់មានពិសពណ៌បៃតងចាស់យកកន្ទុយរុំព័ទ្ធគល់កួរស្រូវមួយកួរ និង ស្លឹកស្រូវមួយសន្លឹកនិងចំកោងក្បាលពីឆ្វេងទៅស្តាំប្រក់ព្រំការពារពីលើកួរស្រូវ។
- ***នៅពីក្រោមខ្សែព្រំនៃផ្ទៃពណ៌បៃតងខ្ចីនិងពណ៌ខៀវ :*** មានអក្សរ "**ត.គ.រស**" ពណ៌ស ។

**គ. ស្លាកសញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់ពាក់លើគម្របហោប៉ៅអាវស្តាំ :** ធ្វើអំពីជ័ររឹងមានផ្ទៃពណ៌ទឹកប៊ិកដែលមានទំហំទទឹង២០មិល្លីម៉ែត្រ បណ្តោយ១០០មិល្លីម៉ែត្រ កម្រាស់០២មីល្លីម៉ែត្រ។ នៅចំហៀងខាងឆ្វេងសញ្ញាសម្គាល់ឈ្មោះមានសញ្ញាសម្គាល់នាយកដ្ឋានកៀវត្រសាស្រ និងកែលំអរដីកសិកម្មទំហំ ១៥មិល្លីម៉ែត្រគុណនឹង១៥មិល្លីម៉ែត្រដែលស្ថិតនៅលើផ្ទៃពណ៌សទំហំ០២មិល្លីម៉ែត្រគុណនឹង២០មិល្លីម៉ែត្រ ។ នៅចំហៀងខាង

ស្តាំមានគូសខណ្ឌដោយបន្ទាត់ពណ៌មាសពាក់កណ្តាលស្របបណ្តោយផ្នែកខាងលើនៃបន្ទាត់បណ្តោយសរសេរឈ្មោះមន្ត្រីភូតគាមអនាម័យជាអក្សរខ្មែរ និង ផ្នែកខាងក្រោមសរសេរឈ្មោះជាអក្សរឡាតាំងពណ៌មាស ។

**ឃ-ស្លាកសញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ :** ធ្វើពីក្រណាត់ដែលមានរាងមូលមានអង្កត់ផ្ចិត ៧០មិល្លីម៉ែត្រ ប៉ាក់នឹងអំបោះសូត្រ ត្រូវបានកំណត់ដូចខាងក្រោមៈ

- **ផ្នែកជុំវិញ :** ព័ទ្ធដោយពណ៌ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលខ្សែពណ៌ខៀវខាងក្រៅមានទទឹង ០២មិល្លីម៉ែត្រ ផ្នែឆ្នូតកណ្តាលពណ៌ក្រហម០៥មិល្លីម៉ែត្រ និង ខ្សែឆ្នូតខៀវខាងក្នុង០១មិល្លីម៉ែត្រ ។ នៅលើផ្នែកខាងលើនៃផ្ទៃជុំវិញនេះមានប៉ាក់អក្សរពណ៌លឿងថា "**មន្ត្រីភូតគាមអនាម័យ**" និងផ្នែកខាងក្រោមមានប៉ាក់អក្សរឡាតាំងពណ៌សថា" PHYTOSANITARY OFFICER" ។
- **ផ្នែកកណ្តាល :** នៅចំផ្នែកកណ្តាល និង ជាផ្ទៃទ្រនាប់ក្រោមដែលមានអង្កត់ផ្ចិត៦២មិល្លីម៉ែត្រ មានពីរពណ៌ដែលពាក់កណ្តាលរង្វង់ខាងក្រោមមានពណ៌បៃតងខ្ចី និង ពាក់កណ្តាលរង្វង់ខាងលើមាន ពណ៌ខៀវ ។
- **នៅលើផ្ទៃរង្វង់ទាំងពីរពណ៌ :** មានព័ទ្ធជុំវិញដោយខ្សែពណ៌សដែលមានកម្រាស់ ០១មិល្លីម៉ែត្រ និង លំអជាភូគោលដោយខ្សែពណ៌សដែលមានកម្រាស់០.៧មិល្លីម៉ែត្រ ជាខ្សែរយៈបណ្តោយ៣ខ្សែ និង ខ្សែរយៈទទឹង៣ខ្សែ ។
- **នៅលើកណ្តាលភូគោល :** មានប៉ាក់រូបពស់មានពិសពណ៌បៃតងចាស់ យកកន្ទុយរុំព័ទ្ធគល់កួរស្រូវមួយកួរ និង ស្លឹកស្រូវមួយសន្លឹក និង ចំកោងក្បាលពីឆ្វេងទៅស្តាំប្រុងប្រយ័ត្នការពារពីលើកួរស្រូវ ។

**ប្រការ ៤ :** មន្ត្រីភូតគាមអនាម័យម្នាក់ៗមានសិទ្ធិទទួល និងប្រើប្រាស់ឯកសណ្ឋាន និងសញ្ញាសម្គាល់ដូចមានកំណត់ក្នុងប្រកាសនេះចំនួនពីរ(២)សម្រាប់ជារបបប្រចាំឆ្នាំ ។

**ប្រការ ៥ :** ក្នុងពេលបំពេញបេសកកម្ម សមត្ថកិច្ចភូតគាមអនាម័យត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងមានលិខិតបញ្ជាបេសកកម្មជាប់នឹងខ្លួន ។

**ប្រការ ៦ :** ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន និង សញ្ញាសម្គាល់របស់សមត្ថកិច្ចភូតគាមអនាម័យត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៧ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ចន្ទ សារុន

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត ក្រុង

-ដូចប្រការ ៨

-ឯកសារ-កាលប្បវត្តិ

# គំរូឯកសណ្ឋាន និងសញ្ញាសំគាល់របស់មន្ត្រីភូតគាមអនាម័យ

មួកកាស្កេត



1) នាយកដ្ឋាន

2) ការិយាល័យ

ថ្នាក់ដឹកនាំ

3 មន្ត្រី ភគអ ជាប្រធានស្នាក់ការ ភគអ

4 មន្ត្រី ភគអ

1) ពណ៌មាស



2) ពណ៌ប្រាក់



3 ពណ៌សំរិទ្ធ



ស្លាកសញ្ញាសម្រាប់ពាក់លើចុងកអាវឆ្វេងស្តាំ




ស្លាកសញ្ញាសម្គាល់ឈ្មោះសម្រាប់ពាក់លើគំរបហោប៉ៅអាវស្តាំ



ស្លាកសញ្ញាសម្គាល់
សម្រាប់ព្យួរលើគំរបហោប៉ៅអាវស្តាំ




ស្លាកសញ្ញាសម្គាល់
សម្រាប់ដេរភ្ជាប់លើដើមដៃអាវស្តាំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

លេខ ១៤៩៧ ប្រក- ដនស/ជសហ

ភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការបង្កើត គណៈកម្មាធិការ កំណត់បុរេលក្ខណៈ សម្បត្តិ វាយតម្លៃ ប្រគល់កិច្ចសន្យា (PEAC) និង បង្កើត អង្គភាពលទ្ធកម្ម (PU) របស់ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ០៣ អ.ន.ក្រប.ក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការប្រគល់ទីតាំង និងអង្គភាពចំណុះអោយមកស្ថិតនៅក្រោម ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦០ អ.ន.ក្រប.ក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង លទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៣១៩ សហវ.មប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តវិធាន និង បទប្បញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញការចាំបាច់ របស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

## សំរេច

__ប្រការ ១__ : បង្កើតគណៈកម្មាធិការ កំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា ( PEAC ) របស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដែលមានសមាសភាព ដូចខាងក្រោម :

១-ឯកឧត្តម **ជា សុផារ៉ា** រដ្ឋលេខាធិការក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ប្រធាន

២-ឯកឧត្តម **កើត សារ៉ាត** អនុរដ្ឋលេខាធិការក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អនុប្រធាន

៣-លោក **នា ច័ន្ទលីដា** អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ សមាជិក

អាស័យដ្ឋាន លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
MLMUPC Tel/Fax: (855-23) 215 660, E-mail : mlmupc@camnet.com.kh ; LMAP Tel\Fax: (855-23) 211 354, E-mail : lmap@camnet.com.kh

| | | | |
|---|---|---|---|
| ៤-លោក | **ទូត ពុទ្ធដារ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៥-លោក | **ង៉ុវ ឧត្តរី** | ប្រធាននាយកដ្ឋានស្ថិតិផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច | សមាជិក |
| ៦-លោក | **តាន់ សេងហៀង** | អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច | សមាជិក |
| ៧-លោកស្រី | **ខៀវ ហ៊ីង** | ប្រធានអង្គភាពលទ្ធកម្ម ( **PU** ) | លេខាធិការ |

គណៈកម្មាធិការនេះមានភារៈកិច្ចទទួលខុសត្រូវ ក្នុងការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃសំណើដេញថ្លៃ និង ប្រគល់កិច្ចសន្យា របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

**ប្រការ ២** : បង្កើតអង្គភាពលទ្ធកម្ម (**PU** ) របស់ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោកស្រី | **ខៀវ ហ៊ីង** | ប្រធានការិយាល័យគ្រប់គ្រងផែនការសេដ្ឋកិច្ច | ប្រធាន |
| ២-លោក | **ហាក់ ហ៊ីន** | អនុប្រធាន ការិយាល័យគណនេយ្យ | អនុប្រធាន |
| ៣-លោកស្រី | **កុសល សុទ្ធិចារ** | ប្រធាន ការិយាល័យគណនេយ្យ | សមាជិក |
| ៤-លោក | **ស៊ុត បូរ៉ែត** | ប្រធានការិយាល័យគ្រប់គ្រង និង ផ្គត់ផ្គង់ | សមាជិក |
| ៥-លោក | **ម៉ុន ឧត្តរា** | អនុប្រធានការិយាល័យ កិច្ចការវិនិយោគ | សមាជិក |
| ៦-លោក | **សុក សុវណ្ណារា** | មន្ត្រីការិយាល័យ គណនេយ្យ | សមាជិក |

**ប្រការ ៣** : ប្រធានអង្គភាពលទ្ធកម្ម ( **PU** ) មានតួនាទីជាលេខាធិការ របស់គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និង ប្រគល់កិច្ចសន្យា ( **PEAC** )។

**ប្រការ ៤** : អង្គភាពលទ្ធកម្ម (**PU** ) របស់ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ មានភារកិច្ច :

១- រៀបចំឯកសារចាំបាច់ (រួមទាំងឯកសារដេញថ្លៃ ដោយប្រគូតប្រជែង) សំរាប់ប្រតិបត្តិលទ្ធកម្ម នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយធ្វើការពិគ្រោះ ឬ ដោយមានការ ឧបត្ថម្ភពីអង្គភាពពាក់ព័ន្ធ ។

២- រៀបចំផ្សព្វផ្សាយអញ្ជើញ អោយចូលរួមដេញថ្លៃ នៅក្នុងសារពត៌មានជាតិ ឬ បរទេស និង ផ្ញើលិខិតសាកសួរថ្លៃទៅអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ។

៣- បញ្ជូនឯកសារដែលដេញថ្លៃ ទៅអោយភាគី ដែលទិញបានឯកសារទាំងនេះ ។

៤- ទទួលសំណើរដេញថ្លៃ ឬ តារាងតម្លៃ ពីអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការដែលចូលរួមព្រមទាំងធ្វើការពិនិត្យ ភាពសមស្រប នៃសំណើដេញថ្លៃ ។

៥- បញ្ជូនការងារលទ្ធកម្ម ដែលចាំបាច់ ទៅនាយកដ្ឋានលទ្ធកម្មសាធារណៈ ហើយរៀបចំ និង បញ្ជូនទំរង់របាយការណ៍ នៃការដេញថ្លៃ ឬ ទំរង់របាយការណ៍លទ្ធកម្ម ។

៦- ផ្ញើលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ ព្រមទាំងរៀបចំចុះហត្ថលេខាលើកិច្ចសន្យាដែលបាន អនុម័តរួចហើយ ។

៧- ត្រួតពិនិត្យការប្រគល់ ទទួល ទំនិញ និង សំណង់ ហើយបញ្ជូនសំណុំឯកសារចាំបាច់ ទៅអង្គភាពហិរញ្ញកិច្ច ដើម្បីធ្វើការទូទាត់ ។

៨- អនុវត្តអោយបានម៉ឺងម៉ាត់ នូវវិធាន និង បទបញ្ញត្តិស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ (ប្រកាសលេខ ៣១៩) ក្នុងការអនុវត្តន៍ កិច្ចលទ្ធកម្ម ជាពិសេសការកំណត់អោយបានត្រឹមត្រូវ នូវ វិធីសាស្ត្រ និង នីតិវិធីលទ្ធកម្ម ។

៩- កំណត់ពេលធ្វើការក្នុងការបំពេញកិច្ចលទ្ធកម្ម និងរ គោរពនូវពេលវេលាដែលបានកំណត់ ។

១០ ពិនិត្យតាមដានដោយដិតដល់ នូវរាល់សកម្មភាពការងារលទ្ធកម្ម ជាមួយក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៥** : រាល់ប្រកាស ឬសេចក្តីសំរេចណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦** : នាយកខុទ្ទកាល័យ និង អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ , អស់លោក ដែលមានឈ្មោះក្នុងប្រការ១ និង ប្រការ ២ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

គាត ឈន់

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- នាយកដ្ឋាន លទ្ធកម្មសាធារណៈ
  - ដូចមាត្រា ៦ ដើម្បីអនុវត្ត
  - ឯកសារ - កាលប្បវត្តិ